# លទ្ធផលសង្ខេបនៃការស្រាវជ្រាវៈ ការសិក្សានៅកម្រិតសហគ្រាសអំពីឧស្សាហកម្មកាត់ដេរ

*ខែ មេសា ឆ្នាំ ២០១០*

## សាវតា

កាលពីពេលថ្មីៗនេះ អង្គការពលកម្មអន្តរជាតិ (ILO) បានធ្វើការសិក្សាស្រាវជ្រាវជាច្រើន ដើម្បីពិនិត្យមើលនូវផលប៉ះពាល់នៃវិបត្តិ ខិនភាពសេដ្ឋកិច្ចជាសកលមកលើឧស្សាហកម្មកាត់ដេរកម្ពុជា។ គោលបំណងចម្បងនៃការសិក្សាទាំងនេះ គឺដើម្បីពង្រឹងការយល់ដឹងរបស់យើងទាំងអស់គ្នាអំពីផលប៉ះពាល់នៃខិនភាពនេះនៅ កម្រិតបុគ្គល សហគ្រាស និងវិស័យកាត់ដេរ វិភាគលើវិធានការឆ្លើយតបដែលបានយកមកប្រើប្រាស់ និងជួយដល់ការតាក់តែង និងការអនុវត្តគោលនយោបាយ និងការអន្តរាគមន៍ជាក់ស្តែងនានា សំដៅគាំទ្រដល់ការងើបឡើងវិញរបស់ឧស្សាហកម្ម និងដល់កំណើននាពេលអនាគត។

លទ្ធផលសង្ខេបនៃការស្រាវជ្រាវនេះបង្ហាញពីលទ្ធផលរកឃើញនៃការសិក្សាដែលទើបបញ្ចប់កាលពីពេលថ្មីៗនេះ ទៅលើរោងចក្រកាត់ដេរក្នុង និងជុំវិញទីក្រុងភ្នំពេញ ដោយគ្របដណ្តប់លើរោងចក្រផលិតសម្រាប់នាំចេញផង និងរោងចក្រម៉ៅការបន្តផង។ ការសិក្សានេះធ្វើឡើងតាមរយៈការសម្ភាសន៍ទល់មុខគ្នា។ អ្នកគ្រប់គ្រងមកពីរោងចក្រចំនួន ៦៦ ត្រូវបានសួរសំណួរជាច្រើន អំពីការងារប្រតិបត្តិការ ផលប៉ះពាល់កម្រិតរោងចក្រក្នុងពេលសេដ្ឋកិច្ចធ្លាក់ចុះ វិធានការឆ្លើយតបដែលបានអនុវត្ត និងការយល់ឃើញនាពេលអនាគត។

ការអង្កេតនេះ គឺជាផ្នែកមួយនៃការសិក្សា ៣ កម្រិត ដែលអង្គការពលកម្មអន្តរជាតិកំពុងអនុវត្តនៅក្នុងរយៈពេល ៩ខែ ដើម្បីស្វែងយល់ឱ្យបានច្បាស់លាស់អំពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម និងទីផ្សារការងារ ដែលខិនភាពសេដ្ឋកិច្ចមានមកលើឧស្សាហកម្មកាត់ដេរ។ រួមគ្នាជាមួយនឹងការអង្កេតកម្រិតសហគ្រាសនេះ ការសិក្សានេះក៏នឹងកំណត់ផងដែរអំពីស្ថានភាពលំបាក ដែលកម្មករនិយោជិតជួបប្រទះ ក៏ដូចជាស្ថានភាពទូទៅនៃវិស័យនេះ ពោលគឺ ចំណុចខ្លាំង ចំណុចខ្សោយ និងសេចក្តីសង្ឃឹមនាពេលអនាគតរបស់ឧស្សាហកម្មនេះ ដែលជាកម្លាំងចលករមួយនៃកំណើនរបស់ប្រទេសកម្ពុជា។[១]

*ការសិក្សានេះគឺជាគំនិតផ្តួចផ្តើមរួមគ្នារវាងអង្គការពលកម្មអន្តរជាតិ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) ហើយត្រូវបានឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (Agence Française de Développement)។ ការសិក្សានេះត្រូវបានអនុវត្តដោយក្រុមហ៊ុនពិគ្រោះយោបល់ BD Link ។*

[១] នេះគឺជាការសិក្សាស្រាវជ្រាវលើអ្នកគ្រប់គ្រងរោងចក្រ ដូច្នេះ លទ្ធផលរកឃើញដែលបង្ហាញនៅទីនេះអាចមិនស្របគ្នាជាមួយលទ្ធផលរកឃើញ ដែលបានរាយការណ៍ដោយអ្នកពាក់ព័ន្ធដទៃទៀតរបស់ឧស្សាហកម្មនេះ ជាពិសេស ដោយកម្មករនិយោជិតកាត់ដេរ។ លទ្ធផលរកឃើញដែលបង្ហាញនៅទីនេះតំណាងឱ្យទស្សនៈរបស់ម្ចាស់រោងចក្រ មិនមែនជាទស្សនៈរបស់អង្គការពលកម្ម អន្តរជាតិឡើយ។

## ទិដ្ឋភាពរួមៈ គំរូតាងនៃការសិក្សា

- **គំរូតាងនៃការសិក្សានេះគ្របដណ្តប់លើរោងចក្រកាត់ដេរចំនួន ៦៦** ដែលក្នុងនោះរោងចក្រចំនួន ៥៦ ជារោងចក្រដែលបានចុះបញ្ជិកានាំចេញ និងរោងចក្រ ១០ ទៀតមិនបានចុះបញ្ជិកា។ ជារឿយៗ រោងចក្រដែលមិនបានចុះបញ្ជិកាសម្រាប់ការនាំចេញ គឺជារោងចក្រម៉ៅការបន្តឱ្យរោងចក្រផលិតសម្រាប់ការនាំចេញ។

- **គ្រប់រោងចក្រនាំចេញទាំងអស់ ត្រូវចុះឈ្មោះជាសមាជិករបស់ GMAC។** គ្រប់រោងចក្រទាំងអស់ (ទាំងនាំចេញ និងមិននាំចេញ) ត្រូវចុះបញ្ជិកាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)។

- **រោងចក្រនាំចេញទាំង ៥៦ ស្មើនឹង ២២% នៃរោងចក្រទាំងអស់ដែលជាសមាជិករបស់ GMAC (គិតមកត្រឹមចុង ខែធ្នូ ឆ្នាំ ២០០៩) ខណៈពេលដែលរោងចក្រ ១០ ដែលនៅសល់ ស្មើនឹង ១១% នៃរោងចក្រមិនមែនជាសមាជិករបស់ GMAC** ដែលបានចុះបញ្ជិកាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[២]

- **រោងចក្រ ដែលជ្រើសរើសមកធ្វើជាគំរូតាងនេះ មានកម្មករនិយោជិតចំនួន ៥៩,៧៨១ នាក់ ដែល ៩០% គឺជាស្ត្រី។**

- **នៅក្នុងឯកសារនេះ ពាក្យ «រោងចក្រនាំចេញ» មានន័យថារោងចក្រដែលជាសមាជិករបស់ GMAC ហើយ «រោងចក្រដែលមិននាំចេញ» សំដៅលើរោងចក្រដែលមិនមែនជាសមាជិករបស់ GMAC។**

## ព័ត៌មានសំខាន់ៗៈ សហគ្រាសវិស័យកាត់ដេរ

- **រោងចក្រស្ទើរតែទាំងអស់ក្នុងឧស្សាហកម្មនេះ គឺជាកម្មសិទ្ធិរបស់បរទេស និងផ្តោតលើការនាំចេញ។** ក៏មានរោងចក្រតូចៗផងដែរដែលគេមិនបានដឹងពីចំនួន ដែលរោងចក្រទាំងនោះផលិតសម្រាប់ទីផ្សារក្នុងស្រុកផង និងសម្រាប់រោងចក្រនាំចេញ (ដែលជាសមាជិករបស់ GMAC) ផង។ គេដឹងតិចតួចប៉ុណ្ណោះអំពីរោងចក្រទាំងនេះ ហើយម្ចាស់រោងចក្រភាគច្រើនដែលបានទាក់ទង បដិសេធមិនព្រមចូលរួម នៅក្នុងការសិក្សាស្រាវជ្រាវនេះ។

- **ជាធម្មតា សមាជិក GMAC នាំចេញស្ទើរតែ ១០០% នៃផលិតផលរបស់ពួកគេ** ខណៈពេលដែលផលិតផលរបស់ក្រុមហ៊ុនមិនមែនសមាជិក GMAC (ដែលធម្មតា ជារោងចក្រម៉ៅការឱ្យរោងចក្រនាំចេញ) ត្រូវបែងចែករវាងទីផ្សារក្នុងស្រុក និងទីផ្សារបរទេស។

- **រោងចក្រនីមួយៗមានទំហំផ្សេងៗគ្នា ប៉ុន្តែទំហំជាមធ្យមនៃរោងចក្រនីមួយៗគឺមានកម្មករនិយោជិតចំនួន ៧០០ នាក់។** ទំហំកម្លាំងពលកម្មជាមធ្យមគឺច្រើនជាង ៩២០ នាក់ ដែលនេះឆ្លុះបញ្ចាំងពីភាពខុសប្លែកគ្នាគួរឱ្យកត់សម្គាល់រវាងរោងចក្រធំ និងរោងចក្រតូច។

- **ជាទូទៅ រោងចក្រនៅមានភាពក្មេងវ័យនៅឡើយ។** រោងចក្រជាង ៨០% បាន នឹងកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជាតិចជាង ១០ ឆ្នាំ។

[២] កម្រិតនៃការឆ្លើយតបទាបរបស់ក្រុមក្រោយនេះ គឺដោយសារតែការស្ទាក់ស្ទើរទូទៅរបស់រោងចក្រទាំងនេះ ក្នុងការចូលរួមលើការសិក្សាស្រាវជ្រាវនេះ។

- **រោងចក្រចំនួន ៥៨% គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំណត់** ខណៈពេលដែល ៣០% ចុះបញ្ជិកាជាឯកកម្មសិទ្ធិ។

- **រោងចក្រចំនួន ៨៥ ភាគរយជួលអាគារសម្រាប់ផលិតកម្មរបស់ខ្លួន (នេះជាសញ្ញាបង្ហាញថា ម្ចាស់រោងចក្រងាយផ្លាស់ទីផលិតកម្មរបស់ ខ្លួនទៅកាន់ប្រទេសផ្សេងទៀត)** ហើយភាគច្រើនបំផុតមកពី វត្ថុធាតុដើមត្រូវបាននាំចូលពីប្រទេសផ្សេងៗ ញឹកញាប់បំផុតពីប្រទេសចិន។

- **ផលិតផលសំខាន់របស់រោងចក្រទាំងនោះ រួមមាន អាវយឺត ខោកាប៊ិយ ខោ សម្លៀកបំពាក់កីឡា ខោអាវក្នុង និងសម្លៀកបំពាក់ពេលយប់។** រោងចក្រភាគច្រើនមានឯកទេសតែលើប្រភេទផលិតផលមួយ ឬពីរ ក្នុងចំណោមផលិតផលទាំងនេះតែប៉ុណ្ណោះ។

## លទ្ធផលរកឃើញទូទៅ

### *ផលប៉ះពាល់នៅកម្រិតរោងចក្រ:*

- **រោងចក្រចំនួន ៨៨% ក្នុងចំណោមរោងចក្រទាំងអស់បានរាយការណ៍ថាបានទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយសារវិបត្តិនេះ។** សម្រាប់រោងចក្រមិននាំចេញវិញ តួលេខនេះគឺ ១០០%។

- **ការបញ្ជាទិញសម្រាប់ការនាំចេញបានធ្លាក់ចុះ សម្ពាធកាន់តែខ្លាំងដើម្បីឱ្យបញ្ចុះតម្លៃ និងតម្លៃខ្ពស់នៃធនធានសម្រាប់ផលិត** ត្រូវបានកំណត់ថាជាសម្ពាធដ៏ខ្លាំងចំនួន ៣ ដែលរោងចក្រទាំងនេះជួបប្រទះ។

- **រោងចក្រមិននាំចេញហាក់បីដូចជាទទួលរងផលប៉ះពាល់ច្រើនជាង ដោយសារតែតម្លៃធនធានក្នុងស្រុកបានកើនឡើងខ្ពស់ ហើយតម្រូវការក្នុងស្រុកបានធ្លាក់ចុះ។**

- **រោងចក្រមិននាំចេញក្នុងភាគរយច្រើនជាង បានជួបប្រទះបញ្ហាអ្នកបញ្ជាទិញមិនទូទាត់ប្រាក់ឱ្យ:** ១០% នៃរោងចក្រមិននាំចេញ បើប្រៀបជាមួយត្រឹមតែ ៤% នៃរោងចក្រនាំចេញ។ ជារឿយៗ រោងចក្រនាំចេញគឺជាអ្នកបញ្ជាទិញដ៏សំខាន់របស់រោងចក្រទាំងនេះ។

- **ខណៈពេលដែលរោងចក្រភាគច្រើន (៦៣%) អាចបង្កើន ឬរក្សាចំណូលរបស់ខ្លួន មុនពេលមានវិបត្តិសេដ្ឋកិច្ច ចំណូលរបស់រោងចក្រភាគច្រើន (៥៨%) មានការថយចុះនៅចន្លោះខែ សីហា ឆ្នាំ ២០០៨ និង ខែ សីហា ឆ្នាំ ២០០៩** (ចាប់ពី ៥% ដល់ ៧៥% និងជាមធ្យម ៣០%)។

- **ខណៈពេលដែលក្រុមហ៊ុនភាគច្រើន (៦៥%) ប្រឈមនឹងការចំណាយកើនឡើង មុនពេលមានវិបត្តិនេះ រោងចក្រចំនួន ២៨% បានរាយការណ៍អំពីការថយចុះនូវការចំណាយអំឡុងពេលមានវិបត្តិនេះ (សីហា ២០០៨ ដល់ សីហា ២០០៩)។** កត្តាសំខាន់ដែលធ្វើឱ្យមានការថយចុះ គឺការថយចុះនូវការចំណាយដែលពាក់ព័ន្ធនឹងផលិតកម្ម ដែលថយចុះក្នុងពេលដែលតម្រូវការសម្លៀកបំពាក់មានការថយចុះ។

### *វិធានការឆ្លើយតប ដែលបានអនុវត្ត:*

- **រោងចក្រជាងពាក់កណ្តាល ក្នុងចំណោមរោងចក្រទាំងអស់បានធ្វើការផ្លាស់ប្តូរកម្លាំងពលកម្ម អំឡុងពេលមានវិបត្តិនេះ។** ការផ្លាស់ប្តូរទាំងនេះ គឺក្នុងទម្រង់ជាការបញ្ឈប់ការងារកម្មករនិយោជិត និងការកាត់បន្ថយទាំងម៉ោងធ្វើការធម្មតា និងម៉ោងធ្វើការបន្ថែម ហើយនិងប្រាក់រង្វាន់ផងដែរ។

- **នៅពេលនិយាយដល់ការផ្លាស់ប្តូរកម្លាំងពលកម្ម រោងចក្រផ្តល់ចម្លើយផ្សេងគ្នាអំពីភាពងាយស្រួលក្នុងការចរចារបស់ពួកគេជាមួយសហជីព។** ខណៈពេលដែលក្រុមហ៊ុនភាគច្រើនបានរាយការណ៍ថាមានការលំបាកតិចតួច ឬមិនមានការលំបាកសោះនៅក្នុង ការចរចាបែបនេះ អ្នកគ្រប់គ្រងជាងមួយភាគប្រាំ (២២%) បាននិយាយថា «ការចរចាមានការលំបាកខ្លាំង»។

- **កម្មករនិយោជិតនៅផ្នែកផលិតកម្ម គឺជាជនរងគ្រោះមុនគេក្នុងវិបត្តិនេះ**នៅក្នុងវិស័យកាត់ដេរ ដោយពួកគេត្រូវរងគ្រោះដោយសារតែការបាត់បង់ការងារ និងវិធានការកែសម្រួលដទៃទៀត។ អ្នកគ្រប់គ្រង និងបុគ្គលិកមិននៅក្នុងផ្នែកផលិតកម្មមិនសូវទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរឡើយ។

- **រោងចក្រនាំចេញចំនួន ៦០% និងរោងចក្រមិននាំចេញចំនួន ៤០% ត្រូវកាត់បន្ថយតម្លៃ**លើផលិតផលរបស់ខ្លួន ដើម្បីជាការឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ច។

- **រោងចក្រជាងមួយភាគបួន (២៧%) បានធ្វើការផ្លាស់ប្តូរគោលនយោបាយជ្រើសរើសបុគ្គលិករបស់ខ្លួន ដោយសារតែវិបត្តិនេះ។** ជាញឹកញាប់បំផុត ការផ្លាស់ប្តូរទាំងនេះគឺក្នុងទម្រង់ (ក) មិនបន្តកិច្ចសន្យាដែលផុតកំណត់ និង (ខ) រឹតបន្តឹងលក្ខខណ្ឌជ្រើសរើសបុគ្គលិក។

- **មានតែរោងចក្រនាំចេញ ៥% ប៉ុណ្ណោះ ដែលផ្តល់ជំនួយដល់កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារ។**[៣] ជាធម្មតាជំនួយបែបនេះស្ថិតក្នុងទម្រង់ជាការផ្តល់ប្រឹក្សា និងដំបូន្មានដល់កម្មករនិយោជិត ឬជួយដល់ពួកគេឱ្យរកការងារថ្មីបានធ្វើ ដោយប្រើប្រាស់បណ្តាញផ្ទាល់ខ្លួន/ក្រៅផ្លូវការ នៅក្នុងរោងចក្រកាត់ដេរដទៃទៀត។[៤]

***ទំនាក់ទំនងវិជ្ជាជីវៈ :***

- **រោងចក្រចំនួន ១៧% បានរាយការណ៍ថាមានវិវាទការងារ នៅក្នុងពេលមានវិបត្តិនេះ** (ពោលគឺចាប់តាំងពីខែ កញ្ញា ឆ្នាំ ២០០៨ មក)។

- **ក្នុងចំណោមវិវាទដែលបានកើតឡើង មានវិវាទត្រឹមតែ ២៥% ប៉ុណ្ណោះ ដែលមានការជាប់ទាក់ទងទៅនឹងវិបត្តិសេដ្ឋកិច្ច។** ភាគច្រើន អ្នកគ្រប់គ្រងបាននិយាយថា វិវាទកើតឡើងដោយសារការយល់ឃើញផ្សេងគ្នារបស់កម្មករនិយោជិត (និងតំណាងកម្មករ និយោជិត) និងអ្នកគ្រប់គ្រងលើបញ្ហាទូទាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់នានា និងការបកស្រាយច្បាប់ការងារផ្សេងគ្នា។[៥]

---

[៣] រោងចក្រមិនមែនជាសមាជិក GMAC បដិសេធមិនឆ្លើយសំណួរនេះ។

[៤] ភាគរយទាបនៅក្នុងលទ្ធផលរកឃើញនេះឆ្លុះបញ្ចាំងពីកង្វះព័ត៌មានជាទូទៅ កង្វះឱកាស និងកង្វះស្ថាប័នដែលផ្តល់ជំនួយពាក់ព័ន្ធនឹងការគ្មានការងារធ្វើសម្រាប់កម្មករនិយោជិតផង និងសម្រាប់និយោជកផង នៅពេលមានវិបត្តិបែបនេះ និងវិបត្តិប្រភេទផ្សេងៗទៀត។

[៥] ប៉ុន្តែ លទ្ធផលរកឃើញនេះត្រូវយកទៅបកស្រាយឱ្យបានប្រុងប្រយ័ត្ន ដោយសារតែពាក្យ «មានទំនាក់ទំនងជាមួយវិបត្តិសេដ្ឋកិច្ច» អាចបំផុសឱ្យមានទស្សនៈផ្ទាល់ខ្លួន ដែលអ្នកពាក់ព័ន្ធក្នុងឧស្សាហកម្មផ្សេងទៀត (គួរកត់សម្គាល់ជាងគេគឺកម្មករនិយោជិតតែម្តង) អាចមិនយល់ស្របតាម។ លើសពីនេះទៅទៀត អាចមានការរាយការណ៍មិនបានគ្រប់គ្រាន់ពីសំណាក់អ្នកគ្រប់គ្រង អំពីការទទួលស្គាល់វិវាទដែលពាក់ព័ន្ធនឹងវិបត្តិនេះ។

- **នៅចន្លោះឆ្នាំ ២០០៨ និង ២០០៩ ការខាតបង់ជាមធ្យម (ជាបន្ទុករបស់និយោជក) ដោយសារការធ្វើកូដកម្មបានកើនឡើងយ៉ាងច្រើនពី** ១៣,០០២ ដុល្លា ដល់ ៣៩,៨២៩ ដុល្លា។ ប៉ុន្តែ ការខាតបង់ជាមធ្យមនេះអាចមិនត្រឹមត្រូវ ដោយសារតែរោងចក្រ ដែលឆ្លើយតបមានចំនួនតិច ហើយការខាតបង់លើកូដកម្មមួយលើកៗមានកម្រិតខុសគ្នាឆ្ងាយ។[៦]

- **នៅក្នុងរយៈពេលតែមួយ ការខាតបង់ជាមធ្យមដោយសារកូដកម្ម និងការតវ៉ានានាបានកើនឡើងចំនួន ៥៧%** ពី ៤,១៥០ ដុល្លា ទៅ ៦,៥២០ ដុល្លា។

## ព័ត៌មានសង្ខេបអំពីរោងចក្រ «ដែលមិនរងផលប៉ះពាល់»

- **រោងចក្រដែលមិនរងផលប៉ះពាល់ មានចំនួនត្រឹមតែ ១២% នៃរោងចក្រដែលបានអង្កេតតែប៉ុណ្ណោះ។**

- **ជាទូទៅរោងចក្រទាំងនេះ គឺជារោងចក្រដែលៈ**

  (ក) ជាសមាជិករបស់ GMAC

  (ខ) មានទំហំធំជាងរោងចក្រដែលរងផលប៉ះពាល់ ហើយជាធម្មតាមានកម្មករនិយោជិតជាង ១000 នាក់

  (គ) មានការលំបាកតិចតួចក្នុងការស្វែងរកកម្មករនិយោជិតជំនាញ

  (ឃ) ពុំមានការលំបាកជាមួយនឹងការអនុលោមតាមច្បាប់ការងារ ជាមួយវិវាទការងារ ឬជាមួយការលួចទំនិញពីរោងចក្រ

  (ង) មានទំនាក់ទំនងស្អិតរមួតជាមួយអ្នកបញ្ជាទិញបរទេស ដែលផ្តល់លទ្ធភាពឱ្យពួកគេរក្សាបាននូវកម្រិតនៃការបញ្ជាទិញ បើទោះបី ជាតម្រូវការក្នុងទីផ្សារជារួមមានការធ្លាក់ចុះក៏ដោយ

## អនាគត

- **អ្នកគ្រប់គ្រងភាគច្រើនមានសុទិដ្ឋិនិយមអំពីអនាគត។** អ្នកគ្រប់គ្រងជាង ៥០% ជឿជាក់ថា ការលក់នឹងកើនឡើងម្តងទៀត នៅក្នុងឆ្នាំ ២០១០។ លើសពីនេះ **អ្នកគ្រប់គ្រងតិចជាង ១០% រំពឹងថានឹងមានការបាត់បង់ការងារបន្ថែមទៀត។**

- **អ្នកគ្រប់គ្រងជិត ៦០% បាននិយាយថា ពួកគេមានគម្រោងជួលបុគ្គលិកថ្មីៗ ឬបុគ្គលិកដែលបានបញ្ឈប់ពីមុនមក នៅក្នុងរយៈពេល ១២ ខែខាងមុខនេះ។** រយៈពេលដែលបុគ្គលិកថ្មីៗទាំងនេះអាចត្រូវបានជួលឱ្យធ្វើការងារ ឬប្រភេទកិច្ចសន្យាដែលផ្តល់ឱ្យពួកគេ (មានថិរវេលាកំណត់ ឬមានថិរវេលាមិនកំណត់) គឺអាស្រ័យទៅតាមភាពរឹងមាំ និងល្បឿននៃការងើបឡើងនៃឧស្សាហកម្មនេះ។

- **អ្នកគ្រប់គ្រងជាង ៥០% រំពឹងថាទំហំកម្លាំងពលកម្មជារួមរបស់ពួកគេនឹងមានការកើនឡើង នៅក្នុងរយៈពេល ១២ ខែទៀត** (ចាប់ពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩)។ ជាមធ្យម អ្នកគ្រប់គ្រងទាំងនេះព្យាករណ៍ថាការកើនឡើង (សុទ្ធ) នឹងមានចំនួន ២០% បើទោះបីជាការរំពឹងទុកមានភាពខុសគ្នាច្រើនរវាងរោងចក្រមួយ និងរោងចក្រមួយទៀតក៏ដោយ។

---

[៦] មានរោងចក្រតែ ៤, ៥ និង ៦ ប៉ុណ្ណោះ ដែលឆ្លើយសំណួរនេះសម្រាប់ឆ្នាំ ២០០៧ ២០០៨ និង ២០០៩។ លើសពីនេះ រោងចក្រមួយនៅក្នុងគំរូតាងនេះ បានខាតបង់លើកូដកម្ម លើសឆ្ងាយជាងការខាតបង់របស់រោងចក្រដទៃទៀត។ នៅពេលដែលដករោងចក្រនេះចេញ មធ្យមភាគរបស់ប៉ាន់គំរូធ្លាក់ចុះយ៉ាងច្រើនមកត្រឹម ១៣,២៣៥ ដុល្លា ដែលនេះបង្ហាញថាមិនមានការផ្លាស់ប្តូរពិតប្រាកដនៃការខាតបង់ជាមធ្យមលើកូដកម្ម នៅក្នុងរោងចក្រឆ្លើយតបភាគច្រើនឡើយ។

- **ប៉ុន្តែ អ្វីដែលជាការព្រួយបារម្ភនោះគឺ អ្នកគ្រប់គ្រង ៧០% ពុំមានផែនការពង្រីកប្រតិបត្តិការរបស់ពួកគេ នៅក្នុងប្រទេសកម្ពុជា នាពេលអនាគតដ៏ខ្លីខាងមុខនេះឡើយ។** មានអ្នកគ្រប់គ្រងតែ ១០% ប៉ុណ្ណោះ ដែលមានគម្រោងពង្រីកប្រតិបត្តិការរបស់ខ្លួន នៅក្នុងរយៈពេល ១២ ខែខាងមុខ ខណៈពេលដែលអ្នកគ្រប់គ្រង ១១% ទៀតនិយាយថា ពួកគេនឹងពង្រីកក្នុងរយៈពេលពី ៣ ទៅ ៥ ឆ្នាំទៀត។

## ឧបសគ្គដែលឧស្សាហកម្មជួបប្រទះ

- **អ្នកគ្រប់គ្រងរោងចក្រក៏ត្រូវបានសួរអំពីទស្សនៈរបស់ពួកគេអំពីឧបសគ្គធំៗ ចំពោះជោគជ័យរបស់ឧស្សាហកម្មកាត់ដេរនាពេលអនាគត។ ឧបសគ្គចំនួន ៥ ដែលត្រូវបានលើកឡើងញឹកញាប់ជាងគេ រួមមាន៖**
  (១) តម្លៃអគ្គិសនីខ្ពស់
  (២) ចំណាយក្រៅផ្លូវការ ឬថ្លៃសេវាជួយសម្រួលខ្ពស់
  (៣) កង្វះកម្លាំងពលកម្មជំនាញ
  (៤) ចំណាយលើធនធានសម្រាប់ផលិតមានកម្រិតខ្ពស់
  (៥) ផលិតភាពទាប

- **ការជ្រៀតជ្រែករបស់រដ្ឋាភិបាល តាមរយៈការបង្កើតបទប្បញ្ញត្តិ បទដ្ឋានការងារ និងការទទួលបានទីផ្សារបរទេស មិនត្រូវបានគេចាត់ទុកថាជាឧបសគ្គចំពោះកំណើនរបស់វិស័យនេះឡើយ។**

## អនុសាសន៍

លទ្ធផលនៃការសិក្សានេះ និងការសិក្សាដទៃទៀតគឺជាមូលដ្ឋាន សម្រាប់ផ្តល់អនុសាសន៍ដូចខាងក្រោមនេះ

(១) **តាមរយៈការសហការជាមួយ GMAC និងរដ្ឋាភិបាល ម្ចាស់រោងចក្រត្រូវពង្រីក និងរកទីផ្សារសម្រាប់ផលិតផលរបស់ពួកគេឱ្យបានច្រើន** ដើម្បីកាត់បន្ថយហានិភ័យសេដ្ឋកិច្ច ដែលកើតឡើងដោយសារការពឹងផ្អែកលើទីផ្សារនាំចេញដ៏តូចចង្អៀត (តែទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប)។ ហើយពួកគេគួរខិតខំស្វែងរកបន្ថែមទៀតពីលទ្ធភាពចូលទៅកាន់ទីផ្សារក្នុងតំបន់អាស៊ី។

(២) **វិបត្តិនេះបង្ហាញពីភាពចាំបាច់ ដែលអ្នកតាក់តែងគោលនយោបាយត្រូវពិនិត្យឱ្យបានដិតដល់បន្ថែមទៀតលើលទ្ធភាពបង្កើនតម្រូវការសម្លៀកបំពាក់កម្ពុជា នៅក្នុងស្រុក។** ក្នុងន័យនេះ អ្នកគ្រប់គ្រងរោងចក្រក៏គួរវាយតម្លៃលើតម្រូវការផ្នែកគុណភាព និងបរិមាណសម្រាប់ទីផ្សារក្នុងស្រុក ក្នុងគោលដៅដើម្បីបង្កើនតម្រូវការ (និងបន្ទាប់មក ការផ្គត់ផ្គង់)។

(៣) បើទោះបីនេះជាអាទិភាពមួយខ្ពស់រួចទៅហើយសម្រាប់រដ្ឋាភិបាល បច្ចុប្បន្ននេះ មានភាពបន្ទាន់ថ្មីមួយ ដែលតម្រូវឱ្យប្រទេសកម្ពុជា**បង្កើតឱ្យមានការផ្គត់ផ្គង់អគ្គិសនី ដែលអាចជឿជាក់បាន និងមានប្រសិទ្ធភាពផ្នែកចំណាយ** ដើម្បីជាប្រយោជន៍សម្រាប់គ្រប់ធុរកិច្ចទាំងអស់ (រួមទាំងឧស្សាហកម្មកាត់ដេរផងដែរ)។ បច្ចុប្បន្ននេះ តម្លៃអគ្គិសនីខ្ពស់គឺជាឧបសគ្គមួយដ៏ចម្បងចំពោះសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់របស់រោងចក្រកាត់ដេរកម្ពុជា។

(៤) ដូចដែលបានកត់សម្គាល់រួចមកហើយ **ប្រទេសកម្ពុជាក៏ត្រូវអភិវឌ្ឍន៍ខ្លួនឯង នៅក្នុងចង្វាក់តម្លៃជាសកលសម្រាប់វាយនភ័ណ្ឌ និងសម្លៀកបំពាក់ផងដែរ។** ចំណុចគន្លឹះ ដើម្បីសម្រេចគោលដៅនេះ គួរជាការបង្កើតមុខងារក្នុងចង្វាក់តម្លៃបន្ថែម ដូចជាការផលិតក្រណាត់ក្នុងស្រុក និងសមត្ថភាពរចនាម៉ូដផលិតផលបន្ថែម ដើម្បីអាចជំនួសការពឹងផ្អែកលើការនាំចូលវត្ថុធាតុដើម និងផលិតកម្មកាត់_ដេរ_កាត់ព្រុយ យ៉ាងហោចណាស់បានមួយផ្នែកដែរ។

(៥) **ការបន្តបង្កើនផលិតភាពរបស់កម្លាំងពលកម្មក៏ជាការចាំបាច់មួយផងដែរ។** ការបង្កើនការលើកទឹកចិត្តសម្រាប់ផលិតភាព គឺជាវិធីមួយ ដើម្បីសម្របសម្រួលឱ្យអាចសម្រេចគោលដៅនេះបាន ដូចជា តាមរយៈការផ្តល់ប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិតធ្វើការតាមបរិមាណផលិតផល (ឬប្រាក់ឈ្នួលសម្រាប់កម្មករនិយោជិតដេរស៊ីបុង) និង តាមរយៈការវិនិយោគលើការបណ្តុះបណ្តាលផ្អែកលើការងារដែលមានគុណភាព និងការបណ្តុះបណ្តាលអ្នកមើលការខុសត្រូវ ផលិតកម្មជាក់ស្តែងក្នុងរោងចក្រ។

(៦) **ថ្លៃសេវាក្រៅផ្លូវការចាំបាច់ត្រូវកាត់បន្ថយនៅកម្រិតអប្បបរមា ហើយនីតិវិធីប្រតិបត្តិការនានាចាំបាច់ត្រូវសម្រួលឱ្យសាមញ្ញ។** ការធ្វើបែបនេះនឹងអាចកាត់បន្ថយការចំណាយលើការធ្វើអាជីវកម្ម ជាលទ្ធផល បង្កើតឱ្យមាននូវលទ្ធផលវិជ្ជមានលើការងារ និងលទ្ធភាពទទួលបានប្រាក់ចំណេញ។

(៧) ដៃគូឧស្សាហកម្ម និងទីភ្នាក់ងាររបស់រដ្ឋាភិបាលនានាចាំបាច់ត្រូវសហការគ្នា ដើម្បី**ជម្រុញឱ្យមានប្រព័ន្ធព័ត៌មានទីផ្សារការងារ និងផ្តល់ការគាំទ្រឱ្យកម្មករនិយោជិតដែលទើបបាត់បង់ការងារទទួលបានព័ត៌មានអំពីការងារ។** ចំណុចគន្លឹះ ដើម្បីកាត់បន្ថយការ បាត់បង់ការងារ និងការទប់ទល់នឹងវិបត្តិសេដ្ឋកិច្ចស្រដៀងគ្នានេះនាពេលអនាគត គឺការបង្កើតគោលនយោបាយទីផ្សារការងារសកម្ម និង សេវាព័ត៌មានសម្រាប់និយោជក និងកម្មករនិយោជិត។

ដើម្បីមើលរបាយការណ៍លំអិត សូមចូលទៅកាន់ www.betterfactories.org